# ច្បាប់

# ស្តីពី

# ការបង្ការ និងការប្រយុទ្ធទប់ស្កាត់

# ការរីករាលដាល

# មេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ ២៣៥៣
ថ្ងៃទី០៥.០៨.០២ម៉ោង ១១:០០
បញ្ជូនទៅ

នស/រកម/០៧០២/០១៥

# ព្រះរាជក្រម

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាល ទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១០ ខែ កក្កដាឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.~**

ច្បាប់នេះ មានគោលដៅ កំណត់ការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីក រាលដាល មេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.~**

ជំងឺអេដស៍ គឺជាជំងឺឆ្លងរីករាលដាលមួយបង្កឡើងដោយមេរោគអេដស៍ និងដែល ទទួល ស្គាល់ថា គ្មានព្រំដែន ផ្នែកដែនដី សង្គម នយោបាយ និង សេដ្ឋកិច្ច ហើយជំងឺនេះ ពុំទាន់មាន ថ្នាំព្យាបាលឱ្យជាសះស្បើយទេ ការរាតត្បាតនៃជំងឺនេះ បាននិងកំពុងធ្វើឱ្យប៉ះពាល់យ៉ាងធន់ធរ ទៅលើ សន្តិសុខស្ថិរភាព និងការអភិវឌ្ឍន៏ សេដ្ឋកិច្ចសង្គម និងទាមទារឱ្យរដ្ឋ ចាត់វិធានការ ឆ្លើយតបជាពហុវិស័យ ដើម្បី ៖

១- ជំរុញឱ្យមានការយល់ដឹង ជាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូប ស្តីពីមូលហេតុ របៀប នៃការចំលង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ ស្កាត់ការរីករាលដាលមេរោគអេដស៍/ ជំងឺអេដស៍ តាមរយៈកម្មវិធីអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយទូទាំងប្រទេស ។

២ - ហាមឃាត់ការរើសអើងគ្រប់ប្រភេទ ចំពោះរាល់បុគ្គលណា ដែលត្រូវបានសង្ស័យ ឬត្រូវបានដឹងថា មានមេរោគ អេដស៍/ជំងឺអេដស៍ ។

៣- ជុំរុញឱ្យមានការប្រុងប្រយ័ត្នជាសកល ចំពោះវិធីសាស្ត្រ និងការអនុវត្តទាំងឡាយ ដែលអាច បង្កឱ្យ មានគ្រោះថ្នាក់ ក្នុងការឆ្លងមេរោគ អេដស៍/ជំងឺអេដស៍ ។

៤- ចាត់វិធានការសមស្រប ចំពោះរាល់កត្តាទាំងឡាយ ដែលធ្វើឱ្យកាន់តែធន់ធរដល់ការ រីករាលដាល មេរោគ អេដស៍/ជំងឺអេដស៍ ។

៥- លើកទឹកចិត្តឱ្យមានតួនាទី ជាសក្តានុពលរបស់បុគ្គល ដែលមានមេរោគអេដស៍/ ជំងឺអេដស៍ ក្នុងការលាតត្រដាងពតិមាន និងបទពិសោធន៏របស់ពួកគេ ដើម្បីចង្អុលបង្ហាញដល់ សាធារណជន ។

៦- បញ្ចូលកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍/ ជំងឺ អេដស៍ ជាកម្មវិធីអាទិភាព ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ។

## ជំពូកទី២
## ការអប់រំ និង ការផ្សព្វផ្សាយពត៌មាន

**មាត្រា ៣.-**

រដ្ឋត្រូវជំរុញការអនុវត្តន៍មួយចំនួនដូចខាងក្រោម :

១-រៀបចំ ឱ្យមានការបញ្ជ្រាបបញ្ចូលចំណេះដឹង ស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងសាលារៀន។ ការអប់រំនេះ ត្រូវបញ្ចូលការបង្រៀនស្តីពី មូលហេតុរបៀបនៃការចម្លងនិងការបង្ការផលវិបាកនៃមេរោគ អេដស៍/ជំងឺអេដស៍ ព្រមទាំងជំងឺកាមរោគដទៃទៀត ជាពិសេសផ្តោតលើបំណិនជីវិត ស្របនិងសីលធម៌ សង្គម តាមរូបភាពការបញ្ជ្រាបបញ្ចូល នៅក្នុងកម្មវិធីសិក្សាតាមគ្រប់គ្រឹះស្ថានសិក្សា ភូមិសិក្សារួមទាំង ការអប់រំ ក្រៅប្រព័ន្ធ។

២-រៀបចំឱ្យមានសិក្ខាសាលា និងការបណ្តុះបណ្តាល បង្ហាត់បង្រៀន ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍ ដល់គ្រូបង្រៀន និង អ្នកបង្ហាត់បង្រៀនផ្សេងទៀត ដែលត្រូវបានចាត់តាំងឱ្យទៅបង្រៀនបន្ត។

៣- រៀបចំឱ្យមានការផ្តល់យោបល់ ពីសំណាក់សហគមន៍ សមាគម អង្គការនានា ក្នុងការអប់រំ ស្តីអំពីមេរោគអេដស៍ នឹងជំងឺអេដស៍។

**មាត្រា ៤.-**

រដ្ឋ រៀបចំឱ្យមានការអប់រំ ស្តីពីមេរោគអេដស៍ និង ជំងឺអេដស៍ បញ្ចូលជាផ្នែកមួយនៃការ ផ្តល់សេវាសុខាភិបាល តាមរយៈគ្រូពេទ្យ និងមន្ត្រីសុខាភិបាល។ ចំណេះដឹង និងសមត្ថភាព របស់គ្រូពេទ្យ និងមន្ត្រីសុខាភិបាល ទាំងនេះ ត្រូវបានទទួលការបំពាក់បំប៉នបន្ថែម រួមមានជំនាញ សម្រាប់ផ្សព្វផ្សាយពតិមាន និងការអប់រំ ស្តីពី មេរោគ អេដស៍ និងជំងឺអេដស៍ ។

ការអប់រំផ្សព្វផ្សាយ ស្តីពីមេរោគអេដស៍ និង ជំងឺអេដស៍ ព្រមទាំងការបំពាក់បំប៉នបន្ថែម ជាភារកិច្ចរបស់អ្នកផ្តល់សេវា ថែទាំសុខភាព នៅក្នុងផ្នែកឯកជន ដើម្បីរួមចំណែកក្នុងការបង្ការ និង ការប្រយុទ្ធទប់ ស្កាត់ការរីករាលដាល មេរោគអេដស៍ និង ជំងឺអេដស៍ ។

ការបំពាក់បំប៉នបន្ថែម ត្រូវរួមបញ្ចូលការពិភាក្សាអំពីបញ្ហាក្រមសីលធម៌ ដែលទាក់ទង ទៅនឹង មេរោគអេដស៍ និង ជំងឺអេដស៍ជា ពិសេសការរក្សាភាពសមាត់ ការគោរពសិទ្ធិបុគ្គល ។

## មាត្រា ៥.-

រៀបចំឱ្យមានការផ្សព្វផ្សាយពត៌មាន និងកម្មវិធី សិល្ប៍អប់រំ នៅតាមប្រព័ន្ធផ្សព្វផ្សាយ របស់រដ្ឋ ដោយឥតបង់ថ្លៃ ដើម្បីឱ្យបានជ្រួតជ្រាបដល់សាធារណជន ។

ការផ្សព្វផ្សាយនេះ ត្រូវប្រើប្រាស់វិធីសាស្ត្រ និងពេលវេលាសមស្រប ដើម្បីធានានូវប្រសិទ្ធភាព ។

## មាត្រា ៦.-

រដ្ឋរៀបចំឱ្យមានការអប់រំពិសេស ផ្តោតទៅលើក្មេងស្រី ស្ត្រីជាមេគ្រួសារ ដោយត្រូវយក ចិត្តទុកដាក់ សំខាន់អំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គម និងបញ្ហាយេនឌ័រ ។

## មាត្រា ៧.-

រដ្ឋ រៀបចំឱ្យមានឯកសារអប់រំ ដល់ភ្ញៀវទេសចរនិង អ្នកឈប់សំចត នៅតាមច្រកចេញ-ចូល អន្តរជាតិ ឯកសារអប់រំនេះ ត្រូវបោះពុម្ពជាភាសាខ្មែរ និង ភាសាផ្សេងៗទៀត តាមការចាំបាច់ ។

**មាត្រា ៨.-**

រដ្ឋ រៀបចំផ្តល់ពត៌មាន ឯកសារអប់រំ ឬ ការចូលរួមក្នុងសិក្ខាសាលាជូនដល់គ្រប់កម្មករខ្មែរ មន្ត្រីការទូត មន្ត្រីរាជការ ស្តីពីមូលហេតុ របៀបនៃការចម្លង ការបង្ការនិងផលវិបាក នៃមេរោគអេដស៍/ ជំងឺអេដស៍ មុននឹងចេញទៅធ្វើការនៅបរទេស។

**មាត្រា ៩.-**

គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវសហការជាមួយ អាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍ រៀបចំឱ្យមានកម្មវិធីអប់រំមេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការដោយត្រូវបញ្ចូលទាំងប្រធានបទ ចំពោះការរក្សាភាពសំងាត់នៅកន្លែងធ្វើការនិងឥរិយាបទចំពោះអ្នកមានមេរោគអេដស៍/ អ្នកជំងឺអេដស៍

ជាមួយគ្នានឹងការអបរំស្តីពី មេរោគអេដស៍/ជំងឺអេដស៍ គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវរៀបចំអោយមានផែនការទៅតាមអាណត្តិ ការងាររបស់ខ្លួន ក្នុងការរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ។

**មាត្រា ១០.-**

រដ្ឋត្រូវចលនាពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ គ្រួសារ អង្គការនានា ព្រះសង្ឃ ក្រុមបព្វជិតសាសនា និងក្រុមអ្នកដែលប្រឈមនឹងគ្រោះថ្នាក់បំផុតដើម្បីរៀបចំផ្តល់ពតិមាននិងការអប់រំ នៅគ្រប់លំដាប់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១១.-**

សម្ភារៈឬវត្ថុធាតុសម្រាប់បង្ការការចម្លងមេរោគអេដស៍ ដែលផ្តល់ដោយលក់ ឬ អំណោយ ត្រូវភ្ជាប់នូវឯកសារអប់រំ ដែលបោះពុម្ពជាភាសាខ្មែរ និងជាភាសាផ្សេងទៀត តាមការចាំបាច់ ហើយក្នុងនោះ មាននិយាយពីវិធីប្រើប្រាស់ត្រឹមត្រូវនូវសម្ភារៈ ឬ វត្ថុធាតុទាំងនោះ និងប្រសិទ្ធភាពរបស់វា ប្រឆាំង នឹងការឆ្លងមេរោគអេដស៍ ។

**មាត្រា ១២.-**

ហាមដាច់ខាតរាល់ការឃោសនា ឬ ផ្សព្វផ្សាយពាណិជ្ជកម្ម ដែលអះអាងពីការព្យាបាល ព្រមទាំង វិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍ ដែលផ្ទុយនឹងវិធានការនានា របស់អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ និងគោលការណ៍បច្ចេកទេស វេជ្ជសាស្ត្រ ។

## ជំពូកទី៣
## វិធីសាស្ត្រ និង ការអនុវត្តដែលមានសុវត្ថិភាព

**មាត្រា ១៣.-**

រាល់វិធីសាស្ត្រ និងការអនុវត្តន៍ទាំងឡាយ ត្រូវធ្វើទៅតាមគោលការណ៍ ណែនាំរបស់អាជាធរជាតិ ប្រយុទ្ធ និងជំងឺអេដស៍ ។

អាជ្ញាធរជាតិ ប្រយុទ្ធនិងជំងឺអេដស៍ ត្រូវពិគ្រោះពិភាក្សា និងសំរបសំរួលជាមួយក្រសួង សុខាភិបាល អង្គភាពជំនាញ ដែលពាក់ព័ន្ធ ដើម្បីកំណត់ និងផ្សព្វផ្សាយនូវគោលការណ ណែនាំស្តីពីការ ប្រុងប្រយ័ត្នជាសកល ចំពោះការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេស ក្នុងកំឡុងពេលវះកាត់ ជាពិសេសក្នុងអំឡុងពេលវះកាត់ កែសម្ផស្ស ធ្វើធ្មេញ អប់សព សាក់ ឬការងារ ដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា។

**មាត្រា ១៤.-**

រាល់ការប្រើប្រាស់ ឈាម ជាលិកា ឬ សរីរាង្គ ត្រូវធ្វើតេស្ត មេរោគអេដស៍បញ្ជាក់ជាមុន ។

**មាត្រា ១៥.-**

មិនអនុញ្ញាតឱ្យមន្ទីរពិសោធន៍ ឬ អង្គភាពណាមួយ យកឈាម ជាលិកា ឬ សរីរាង្គ ទុកសម្រាប់ ប្រើប្រាស់ដោយពុំបានធ្វើតេស្តមេរោគអេដស៍ បញ្ជាក់ជាមុនឡើយ ។

**មាត្រា ១៦.-**

សាច់ញាតិ ឬអ្នកទទួលឈាម ជាលិកា ឬសរីរាង្គ មានសិទ្ធិសុំធ្វើតេស្តសាជាថ្មី មុននឹងធ្វើការ ចាក់បញ្ចូលឈាម បណ្តុះជាលិកា ឬ ប្តូរសរីរាង្គ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់ ។

**មាត្រា ១៧.-**

ឈាម ជាលិកា និង សរីរាង្គ ដែលមានមេរោគអេដស៍ ត្រូវតែកំទេចចោលតាមគោលការណ៍ អនាម័យត្រឹមត្រូវបំផុត។ ក្នុងករណីចាំបាច់ ឈាម ជាលិកា ឬ សរីរាង្គ ដែលមានមេរោគអេដស៍ អាចទទួលយកបានសម្រាប់តែសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រប៉ុណ្ណោះ។

**មាត្រា ១៨.-**

ហាមឃាត់ដាច់ខាតចំពោះអ្នកដែលដឹងថាខ្លួនមាន មេរោគអេដស៍/ជំងឺអេដស៍ទៅប្រព្រឹត្តក្នុងចេតនាចំលងទៅអ្នកដទៃ ។

## ជំពូកទី៤
## ការធ្វើតេស្ត និង ការផ្តល់កិច្ចប្រឹក្សា

**មាត្រា ១៩.-**

ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តនិងត្រូវមានការយល់ ព្រម ជាមុនពីសាមីជនផ្ទាល់ ។ ចំពោះសាមីជនជាអនីតិជន តម្រូវឱ្យមានការយល់ ព្រមជាលាយលក្ខណ៍អក្សរពីអាណាព្យាបាលស្របច្បាប់ ។

បើការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាណាព្យាបាលស្របច្បាប់ ពុំអាចធ្វើបានការធ្វើ តេស្ត មេរោគអេដស៍/ជំងឺអេដស៍ អាចប្រព្រឹត្តទៅបានដោយគ្រាន់តែមានការព្រមព្រៀងពីអនីតិជន ប្រសិនបើការធ្វើតេស្តនេះផ្តល់អត្ថប្រយោជន៍ផ្ទាល់ចំពោះអនីតិជននោះ។

ចំពោះជនវិកលចរិក រដ្ឋត្រូវយកចិត្តទុកដាក់ ។

**មាត្រា ២០.-**

ហាមដាច់ខាតចំពោះការដាក់ល័ក្ខខ័ណ្ឌឱ្យធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ មុននិងក្រោយការ អនុញ្ញាត ឱ្យចូលបំរើការងារចូលសិក្សានៅក្នុងគ្រឹះស្ថានសិក្សានានា ក៏ដូចជាសម្រាប់ការអនុវត្តសេរីភាព ស្នាក់នៅសិទ្ធិ ធ្វើដំណើរការផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ ឬ សេវាកម្មផ្សេងទៀត ។

**មាត្រា ២១.-**

ការធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ ដោយបង្ខំត្រូវអនុញ្ញាតតែក្នុងករណី មានសេចក្តីបង្គាប់ របស់តុលាការ ។

**មាត្រា ២២.-**

រាល់ការធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើដោយអនាមិក ។

ក្រសួងសុខាភិបាល ត្រូវរៀបចំផ្តល់នូវយន្តការសម្រាប់ធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ ហើយត្រូវធានាភាពអនាមិក និងរក្សាភាពសំងាត់ផ្នែកវេជ្ជសាស្ត្រនៅក្នុងដំណើរការធ្វើតេស្ត ។

**មាត្រា ២៣.-**

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍ អាចផ្តល់សេវានេះបាន លុះត្រាតែមានច្បាប់ អនុញ្ញាត ពីក្រសួងសុខាភិបាល ។ ក្រសួងសុខាភិបាលត្រូវសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីកំណត់និងរក្សានូវស្តង់ដារសេវាមួយសមស្រប ។

**មាត្រា ២៤.-**

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ត្រូវផ្តល់កិច្ចប្រឹក្សាមុន និងក្រោយការធ្វើតេស្តដល់ជន ដែលមកសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ។ អ្នកផ្តល់កិច្ចប្រឹក្សានេះ ត្រូវមានសមត្ថភាព គ្រប់គ្រាន់ សមស្របតាម ស្តង់ដារកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា ២៥.-**

អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ និង ក្រសួងសុខាភិបាល ត្រូវសហការគ្នា រៀបចំ និង លើកកំពស់សមត្ថភាពសម្រាប់ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ដល់គ្រប់កន្លែងធ្វើតេស្ត ដែលមាន ច្បាប់អនុញ្ញាត ហើយធានាឱ្យមានការបណ្តុះបណ្តាល បុគ្គលិកជំនាញ សម្រាប់ផ្តល់សេវាបែបនេះ នៅក្នុងទីកន្លែងធ្វើតេស្តមេរោគអេដស៍/ ជំងឺអេដស៍ ។

# ជំពូកទី ៥
# សេវាសុខាភិបាល និង សេវាគាំទ្រ

**មាត្រា ២៦.-**

រដ្ឋ ត្រូវធានាឱ្យអ្នកដែលមានមេរោគអេដស៍ និង អ្នកជំងឺអេដស៍ ទទួលបាននូវសេវាថែទាំ សុខភាពបឋម ដោយឥតបង់ថ្លៃតាមបណ្តាញសុខាភិបាលទាំងអស់របស់រដ្ឋ និង ត្រូវលើកទឹកចិត្ត ឱ្យមានការចូលរួមពីផ្នែកឯកជន ។

**មាត្រា ២៧.-**

រដ្ឋត្រូវចលនាពង្រឹង ការចូលរួម របស់ប្រជាពលរដ្ឋ គ្រួសារ អង្គការនានា ព្រះសង្ឃ ក្រុមបុព្វជិតសាសនា និង ក្រុមអ្នកដែលប្រឈមនឹងគ្រោះថ្នាក់បំផុត សំដៅឧបត្ថម្ភ ថែទាំ និងព្យាបាល អ្នកមានមេរោគអេដស៍ និង ជំងឺអេដស៍ នៅគ្រប់លំដាប់ថ្នាក់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

រដ្ឋ ត្រូវយកចិត្តទុកដាក់ជំរុញឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់អ្នកមានមេរោគអេដស៍ និង អ្នកជំងឺអេដស៍ ដើម្បីប្រកបរបរចិញ្ចឹមជីវិត និង កម្មវិធីជួយខ្លួនឯង ។ អ្នកមានមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ត្រូវមានសិទ្ធិចូលរួមពេញលេញនៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង កម្មវិធី ជួយខ្លួនឯង ដើម្បីជាមធ្យោបាយចិញ្ចឹមជីវិត ។

**មាត្រា ២៩.-**

រដ្ឋ ត្រូវយកចិត្តទុកដាក់បន្តជំរុញការបង្ការទប់ស្កាត់ និងការគ្រប់គ្រងជំងឺកាមរោគ ក្នុងគោលដៅជួយទប់ស្កាត់ការឆ្លងរាលដាល នៃមេរោគអេដស៍/ជំងឺអេដស៍ ។

# ជំពូកទី៦
## ការតាមដានត្រួតពិនិត្យ

**មាត្រា ៣០.-**

រដ្ឋ ត្រូវបង្កើតកម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យបានទូលំទូលាយមួយ ដើម្បីកំណត់អំពីទំហំ ភាពងាយប្រឈមមុខនឹងគ្រោះថ្នាក់របស់ប្រជាពលរដ្ឋ ការប្រព្រឹត្តរួមភេទ ។

កម្មវិធី នេះ មានគោល បំណងផ្ទៀងផ្ទាត់ វាយតំលៃពីភាពគ្រប់គ្រាន់ ប្រសិទ្ធិភាព និងនិរន្តរភាព នៃវិធានការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងប្រទេស ។

**មាត្រា ៣១.-**

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍ និងជំងឺអេដស៍ ត្រូវកំណត់យកវិធានការ ក្នុងការធានាចំពោះការរក្សាភាពសំងាត់នៃរបាយការណ៍ កំណត់ត្រាវេជ្ជសាស្ត្រ ពត៌មានផ្ទាល់ខ្លួន រួមបញ្ចូលទាំងពត៌មានទាំងអស់ ដែលអាចទទួលបានពីប្រភពពត៌មានផ្សេងៗ ក្នុងការអនុវត្តន៏កម្មវិធីតាមដានត្រួតពិនិត្យ ។ កម្មវិធីតាមដាន ត្រួតពិនិត្យនេះ ត្រូវប្រើប្រាស់នូវប្រព័ន្ធលេខកូដ ដើម្បីធានាឱ្យមានភាពអនាមិក ។

**មាត្រា ៣២.-**

ការតាមរកប្រភពចម្លងមេរោគអេដស៍/ជំងឺអេដស៍ និងសកម្មភាពស្រាវជ្រាវសំងាត់ផ្សេងៗ ទាក់ទង នឹងសុខភាព អាចត្រូវបន្តតាមដានដោយក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ប្រសិនបើ សកម្មភាព ទាំងអស់នោះ មិនផ្ទុយទៅនឹងគោលបំណងទូទៅនៃច្បាប់នេះ ។ ពត៌មានដែលទទួលបានត្រូវរក្សា ភាព សំងាត់ និងត្រូវទុកដាក់ ឱ្យបានត្រឹមត្រូវ ។

# ជំពូកទី ៧
# ការរក្សាភាពសំងាត់

**មាត្រា ៣៣.-**

អ្នកមាន មេរោគអេដស៍ /ជំងឺអេដស៍ ត្រូវទទួលបាននូវការរក្សាភាពសំងាត់ ។

អ្នកមានអាជីពផ្នែកវេជ្ជសាស្ត្រ កម្មករ និយោជក ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនានា ក្រុមហ៊ុនធានា រ៉ាប់រង អ្នកបញ្ចូលទិន្នន័យ អ្នករក្សាសំណុំឯកសារទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងអ្នកដែលមាន ភារកិច្ចពាក់ព័ន្ធ ផ្សេងៗទៀត ត្រូវបានទទួលការណែនាំ ឱ្យមានការយកចិត្តទុកដាក់ ពីការរក្សាភាពនៅក្នុងទំនាក់ទំនងការងារ ជាពិសេស អត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួន របស់ជនដែលមានមេរោគអេដស៍ ។

**មាត្រា ៣៤.-**

ការរក្សាភាពសំងាត់ផ្នែកវេជ្ជសាស្ត្រ ត្រូវលើកលែងនៅក្នុងករណី :

ក- តម្រូវឱ្យធ្វើរបាយការណ៍ ដែលស្របទៅនឹងកម្មវិធីតាមដាន ត្រួតពិនិត្យរក មេរោគអេដស៍ / ជំងឺអេដស៍ ដូចដែលបានចែងក្នុងមាត្រា៣០នៃច្បាប់នេះ

ខ- ផ្តល់ពត៌មានទៅដល់បុគ្គលិកសុខាភិបាល ដែលធ្វើការព្យាបាល ឬថែទាំអ្នកមាន មេរោគអេដស៍ / ជំងឺអេដស៍ ដោយផ្ទាល់ ឬ ដោយប្រយោល និង

គ- ឆ្លើយតបទៅនឹងដីកាចេញដោយតុលាការ ចំពោះបញ្ហាសំខាន់ទាក់ទងទៅនឹងការមាន មេរោគអេដស៍/ជំងឺអេដស៍ របស់បុគ្គលណាម្នាក់ ។ ភាពសំងាត់នៃកំណត់ត្រាវេជ្ជសាស្ត្រ ត្រូវដាក់ក្នុងស្រោមបិទឱ្យ បានត្រឹមត្រូវ ដោយអ្នកគ្រប់គ្រងឯកសារ បន្ទាប់ពីត្រូវត្រួតពិនិត្យ យ៉ាងហ្មត់ចត់ ដោយអ្នកមាន ភារៈទទួលខុសត្រូវ ព្រមទាំងប្រគល់ឱ្យ ដោយផ្ទាល់ដៃ និង បើកជាផ្លូវការ ដោយចៅក្រម នៅចំពោះមុខអង្គជំនុំជំរះក្តីសំងាត់ ។

**មាត្រា ៣៥.-**

លទ្ធផលនៃការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ អាចផ្តល់ឱ្យ :

ក- ជនដែលសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ដោយស្ម័គ្រចិត្ត

ខ- អាណាព្យាបាលស្របច្បាប់របស់អនីតិជន ដែលត្រូវបានធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ក្នុងករណី ជនវិកលចរិត ឬ កូនកំព្រា ត្រូវផ្តល់ឱ្យអាណាព្យាបាលស្របច្បាប់

គ- ជនដែលត្រូវបានអនុញ្ញាតឱ្យទទួលលទ្ធផលនេះ សម្រាប់កម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍ /ជំងឺអេដស៍ ដូចដែលមានចែងក្នុងមាត្រា៣០នៃច្បាប់នេះ និង

ឃ- តាមតម្រូវការរបស់តុលាការ ដូចមានចែងក្នុងចំណុច " គ " មាត្រា ៣៤នៃច្បាប់នេះ ។

## ជំពូកទី៨
## គោលនយោបាយ និង សកម្មភាពនៃការរើសអើង

**មាត្រា ៣៦.-**

ហាមដាច់ខាត ការរើសអើងដល់ជនណាម្នាក់ តាមបែបណាមួយ គិតពីមុន និងក្រោយ ពេលឱ្យចូល បំរើការងារ រួមទាំងការជួល ការដំឡើងឋានន្តរសក្តិ ការចាត់ឱ្យបំពេញការងារ ការរួមរស់ នៅក្នុងសង្គម ដោយផ្អែកលើការដឹង ឬសង្ស័យថា ជននោះ ឬ ក្រុមគ្រួសាររបស់ជននោះ មានមេរោគ អេដស៍ /ជំងឺអេដស៍។ ត្រូវចាត់ទុកថា ខុសច្បាប់ រាល់ការបញ្ឈប់ពីការងារចំពោះជនណាម្នាក់ ដោយផ្អែក លើការដឹងថា ឬសង្ស័យថា ជននោះ ឬ ក្រុមគ្រួសារ របស់ជននោះ មានមេរោគអេដស៍ /ជំងឺអេដស៍។

**មាត្រា ៣៧.-**

គ្រប់ស្ថាប័នអប់រំបណ្តុះបណ្តាលទាំងអស់ មិនត្រូវបដិសេធបណ្តេញ ដាក់វិន័យដាក់ ឱ្យនៅដាច់ដោយឡែក ឬ មិនអនុញ្ញាតឱ្យចូលរួមទទួលផលប្រយោជន៍ ឬសេវាផ្សេងៗ ចំពោះសិស្ស និស្សិតណាម្នាក់ ដោយ សារតែការដឹង

ឬសង្ស័យថា សិស្ស និស្សិតនោះ ឬក្រុមគ្រួសាររបស់សិស្ស និស្សិតនោះមាន មេរោគអេដស៍ /ជំងឺអេដស៍ ។

**មាត្រា ៣៨.-**

អ្នកមានមេរោគអេដស៍/ជំងឺអេដស៍មានសិទ្ធិពេញលេញក្នុងការស្នាក់នៅនិងធ្វើដំណើរ ។

គ្មានជនណាម្នាក់ត្រូវបានគេឃុំឃាំងឱ្យនៅដោយឡែក ដាក់ឱ្យនៅឯកោ មិនអនុញ្ញាតឱ្យចូលស្នាក់ នៅ រួមដំណើរ ឬ បណ្តេញចេញ ដោយសារតែដឹងឬសង្ស័យថា ជននោះ ឬក្រុមគ្រួសាររបស់ជននោះ មាន មេរោគអេដស៍ /ជំងឺអេដស៍ ។

**មាត្រា ៣៩.-**

ហាមដាច់ខាតការរើសអើងចំពោះអ្នក មានមេរោគអេដស៍/ជំងឺអេដស៍ ក្នុងការ ទទួលតំណែងសាធារណៈ ។

សិទ្ធិក្នុងការស្វែងរកតំណែងសាធារណៈ ដោយការបោះឆ្នោត ឬការចាត់តាំងដំឡើងឋានៈ មិនត្រូវ បដិសេធចំពោះជនណាម្នាក់ ដោយគ្រាន់តែដឹង ឬ សង្ស័យថា ជននោះ ឬក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍ /ជំងឺអេដស៍ ។

**មាត្រា ៤០.-**

ហាមឃាត់ដាច់ខាតការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ ក្នុងការទទួល ឥណទាន និង ការខ្ចីបុល ទាំងអស់ រួមទាំងការធានារ៉ាប់រងសុខភាព គ្រោះថ្នាក់និងអាយុជីវិត ក្នុងករណីដែល សាមីជន បំពេញបាននូវលក្ខខណ្ឌ បច្ចេកទេស ដូចពលរដ្ឋធម្មតាដែរ ។

**មាត្រា ៤១.-**

ហាមដាច់ខាតនូវការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងមន្ទីរពេទ្យ និង អង្គភាពសុខាភិបាលនានា ។

គ្មានជនណាម្នាក់ ត្រូវបានបដិសេធមិនឱ្យទទួល សេវាថែទាំសុខភាព ទាំងរដ្ឋ និងឯកជន ឬ ត្រូវបាន ទារតម្លៃខ្ពស់ ដោយសារតែការដឹងថា ជននោះ ឬ ក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍ /ជំងឺ អេដស៍ ។

**មាត្រា ៤២.-**

អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ មានសិទ្ធិដូចជាប្រជាពលរដ្ឋធម្មតា ដូចដែលមានចែងនៅ ក្នុងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី៩
## អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ.)

**មាត្រា ៤៣.-**

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីដឹកនាំ និង អនុវត្តការងារបង្ការ និងការ ប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៤.-**

នាយករដ្ឋមន្ត្រី ត្រូវបានតែងតាំងជាប្រធានអាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ ។ ក្នុងករណី ដែលនាយក រដ្ឋមន្ត្រី មិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាច ចាត់តាំង សមាជិក រាជរដ្ឋាភិបាលម្នាក់ ជំនួស ។

**មាត្រា ៤៥.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវកំណត់ ដោយអនុក្រឹត្យ ។

**មាត្រា ៤៦.-**

រដ្ឋ ត្រូវបញ្ចូលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ជាការងារអាទិភាព នៃកម្មវិធីអភិវឌ្ឍជាតិ នឹងត្រូវ ជំរុញ និង សម្រួល ក្នុងការផ្តល់ថវិកាប្រចាំឆ្នាំ ឱ្យបានទាន់ពេលវេលា ដើម្បីឱ្យកម្មវិធីនេះ ទទួលបាននូវប្រសិទ្ធភាព ។

ថវិការបស់អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានរៀបចំសំរាប់ក្រសួងពាក់ព័ន្ធ ខេត្ត-ក្រុង ទូទាំង ព្រះរាជាណាចក្រកម្ពុជា និងត្រូវបានចាត់ជាថវិកាឧបសម្ព័ន្ធ របស់ក្រសួងសុខាភិបាល និង ត្រូវបានបញ្ចូលទៅក្នុងជំពូក ថវិការអាទិភាព ។

**មាត្រា ៤៧.-**

ដើម្បីធានាប្រសិទ្ធភាពនៃការឆ្លើយតបជាពហុវិស័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវទទួល បន្ទុកក្នុងការ កៀងគរប្រភពធនធានទាំងក្នុងប្រទេស សម្របសម្រួល និងតំរង់ការប្រើប្រាស់ ប្រភពធនធានទាំងនេះដល់ស្ថាប័នពាក់ព័ន្ធ ស្របទៅតាមស្ថានភាព និង តម្រូវការជាក់ស្តែង នៃកម្មវិធីផែនការយុទ្ធសាស្ត្រជាតិ ។

## ជំពូកទី១០

## ទោសប្បញ្ញត្តិ

**មាត្រា ៤៨.-**

ជនណាដែលប្រព្រឹត្តផ្ទុយ នឹងមាត្រា១២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ពី ៥០០.០០០៛ ( ប្រាំសែន រៀល) ដល់ ១.០០០.០០០៛( មួយលានរៀល ) និងត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ ( មួយ) ខែ ដល់ ១ ( មួយ) ឆ្នាំ ។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេ មួយជាពីរ ។ ឯមន្ត្រីរាជការ ត្រូវទទួល ទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៤៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា១៣ មាត្រា១៤ មាត្រា១៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ពី ៥០០.០០០៛ ( ប្រាំសែនរៀល ) ដល់ ១.០០០.០០០៛ ( មួយលានរៀល ) និងត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ៦( ប្រាំមួយ )ខែ ដល់ ១( មួយ )ឆ្នាំ ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោស ទ្វេដាពីរ ។ ទោសនេះ ពុំទាន់រាប់បញ្ចូលនូវការទទួលខុសត្រូវ លើសំណងផ្នែករដ្ឋប្បវេណី និងការដកហូត អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ដែលពាក់ពន្ធ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៥០.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០( ដប់ )ឆ្នាំ ដល់ ១៥( ដប់ប្រាំ )ឆ្នាំ ។

**មាត្រា ៥១.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា២៣ មាត្រា៣១ ឬ មាត្រា៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥០.០០០៛ ( ប្រាំម៉ឺន រៀល )ដល់ ២០០.០០០៛ ( ពីរសែនរៀល )និងត្រូវ ផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ ( មួយ) ខែ ដល់៦ ( ប្រាំមួយ) ខែ ។ ករណីពុំរាងចាលត្រូវផ្តន្ទាទោស ទ្វេមួយជាពីរ ។ ឯមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៥២.-**

ជនណាដែលប្រព្រឹត្តផ្ទុយ នឹងមាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ មាត្រា៤០ ឬ មាត្រា៤១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០៛ ( មួយសែនរៀល) ដល់ ១.០០០.០០០៛ ( មួយលានរៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ )ខែ ដល់ ៦( ប្រាំមួយ )ខែ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

# ជំពូកទី ១១

# អវសានប្បញ្ញត្តិ

**មាត្រា ៥៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់បំផុត

**ប្រមុខរដ្ឋស្តីទី**

[illegible]

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**ជា ស៊ីម ឧត្តមបុត្តិ**

បានយក[illegible]ក្រាបបង្គំ[illegible]

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ១៧០ ជ.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ [illegible]

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**